ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា

## លោកជំទាវ នាង ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីប្រកាសផ្សព្វផ្សាយលទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤ ដែល ធនាគារជាតិនៃកម្ពុជា បានសហការអង្កេតជាមួយ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ នៅសណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦

**សូមគោរព**!

- ឯកឧត្តម **ហោ ដារិទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងផែនការ
- លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
- លោកជំទាវ **ជា សិរី** អគ្គនាយកបច្ចេកទេស ធនាគារជាតិ នៃកម្ពុជា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

ថ្ងៃនេះ តាងនាម **ឯកឧត្តម ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីសោមនស្សរីករាយបំផុតដោយបានចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយអំពី **លទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** ជាសមិទ្ធិផលដំបូងរួមគ្នារវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលកើតឡើងពីការចុះកិច្ចព្រមព្រៀងរួមគ្នានាខែមិថុនា ឆ្នាំ២០១៥ ។ លទ្ធផលនេះនឹងត្រូវបានប្រើប្រាស់ជាធាតុចូលដ៏សំខាន់ ដើម្បីពង្រឹងគុណភាពស្ថិតិវិនិយោគផ្ទាល់បរទេស ដែលជាសមាសធាតុចម្បងមួយរបស់ស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់កម្ពុជា និងដើម្បីឆ្លើយតបការកើនឡើងតម្រូវការឥតឈប់ឈរពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ រួមមាន រាជរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ អ្នកសិក្សាស្រាវជ្រាវ និងអ្នកវិនិយោគ ជាដើម ។

ក្នុងបរិបទនៃសាកលភាវូបនីយកម្ម សមាហរណកម្មទីផ្សារដើមទុនអន្តរជាតិបាននាំឲ្យមានកំណើនខ្លាំងនៃលំហូរវិនិយោគផ្ទាល់បរទេសចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៩០មក និងជាកត្តានាំឲ្យកើនឡើងសេដ្ឋកិច្ចពិភពលោក និងពាណិជ្ជកម្មផងដែរ ។ ផ្ទុយពីលំហូរដើមទុនរយៈកាលខ្លី វិនិយោគផ្ទាល់បរទេសត្រូវបានចាត់ទុកថាជាសារធាតុខ្លាញ់ល្អ (good cholesterol) ដោយសារតែការវិនិយោគប្រភេទនេះមានចក្ខុវិស័យវែងឆ្ងាយ និងផ្តល់នូវគុណប្រយោជន៍ជាច្រើន ។ លំហូរដើមទុនក្នុងទម្រង់ជាវិនិយោគផ្ទាល់បរទេសបានផ្តល់នូវគុណប្រយោជន៍ជាច្រើនដល់ប្រទេសជាអ្នកទទួល ពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដែលគុណសម្បត្តិទាំងនោះ រួមមាន ៖ (១) ការផ្ទេរបច្ចេកវិទ្យាពីប្រទេសអភិវឌ្ឍន៍មកកាន់ប្រទេសកំពុងអភិវឌ្ឍន៍ (២) បង្កើនឱកាសការងារដល់ប្រជាជន និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដល់និយោជិតពីប្រតិបត្តិការអាជីវកម្មថ្មីៗ ដែលយន្តការនេះ បានរួមចំណែកដល់ការកសាងធនធានមនុស្ស និងកាត់បន្ថយភាពក្រីក្រ និង (៣) រួមចំណែកដល់កំណើនថវិកាជាតិ តាមរយៈការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាស ។

ក្នុងបរិការណ៍នៃប្រទេសកម្ពុជា សេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយបានរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបានប្រែក្លាយពីសេដ្ឋកិច្ចដែលពឹងផ្អែកស្ទើរទាំងស្រុងលើវិស័យកសិកម្ម និងផលិតកម្មខ្នាតតូចមកជាប្រទេសដែលអាស្រ័យលើវិស័យឧស្សាហកម្មធុនស្រាល និងវិស័យសេវាកម្ម ។ យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៦ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ប្រមាណ ៧% ចាប់តាំងពីឆ្នាំ២០១១ មក ហើយរំពឹងថានឹងបន្តរហូតទៅដល់ឆ្នាំ២០១៧ ដែលជាសេដ្ឋកិច្ចមួយមានកំណើនលឿនជាងគេនៅក្នុងពិភពលោក នឹងអាចក្លាយជាប្រទេសសេដ្ឋកិច្ចខ្លាថ្មីមួយនៅអាស៊ី ។ លទ្ធផលនៃការរីកចម្រើននេះបានរួមចំណែកដោយការវិនិយោគផ្ទាល់បរទេស ដែលត្រូវបានចាត់ទុកជាសសរស្តម្ភដ៏រឹងមាំមួយដើម្បីធានាឲ្យមានស្ថេរភាពនៃកំណើនសេដ្ឋកិច្ច ។ ជាទូទៅ ចំពោះការវិនិយោគឆ្លងដែន អ្នកវិនិយោគតែងតែពិនិត្យមើលកត្តាសំខាន់ៗ ដូចជា ប្រាក់ឈ្នួលពលកម្ម ថ្លៃវត្ថុធាតុដើម ហេដ្ឋារចនាសម្ព័ន្ធ ផលិតភាពខ្ពស់នៃកម្លាំងពលកម្ម កម្រិតជំនាញ បរិយាកាសអាជីវកម្ម បទបញ្ញត្តិមិនរឹតត្បិតខ្លាំង ។ល។ ការកើនឡើងលំហូរចូលនៃវិនិយោគផ្ទាល់បរទេសយ៉ាងឆាប់រហ័សនៅកម្ពុជា ជាសមិទ្ធិផល និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញអ្នកវិនិយោគបរទេស តាមរយៈការបង្កើតបរិយាកាសវិនិយោគល្អ ការរៀបចំច្បាប់និងបទបញ្ញត្តិស្តីពីការវិនិយោគប្រកបដោយការលើកទឹកចិត្តច្រើនដល់អ្នកវិនិយោគ ការបង្កើតអាជ្ញាធរទទួលបន្ទុកការវិនិយោគ ( ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ) ការធ្វើកំណែទម្រង់បែបបទរដ្ឋបាល ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជាដើម ។

*ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!*

ខ្ញុំសូមជម្រាបជូនថា ដោយសារភាពចាំបាច់នៃស្ថិតិវិនិយោគផ្ទាល់បរទេស ដូចបានរៀបរាប់ខាងលើ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានសម្រេចចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀង ស្តីពី **ការអង្កេតវិនិយោគផ្ទាល់បរទេស** នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ក្នុងគោលបំណងប្រមូល និងចងក្រងស្ថិតិនេះ ដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ជាតិ និងអន្តរជាតិ ។

លទ្ធផលអង្កេតនេះត្រូវបានប៉ាន់ស្មានបំពេញបន្ថែមជាមួយទិន្នន័យរដ្ឋបាលពីក្រសួង-ស្ថាប័ននានា ទិន្នន័យពីប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសមួយចំនួន ទិន្នន័យរបស់ប្រទេសជាដៃគូ និងប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីធ្វើការប៉ាន់ស្មានអំពីកម្រិតនៃវិនិយោគផ្ទាល់បរទេសសរុបឆ្នាំ២០១៤ និងធ្វើការកែតម្រូវត្រឡប់ក្រោយនូវទិន្នន័យចេញផ្សាយកន្លងមកដល់ឆ្នាំ២០១០ ។

យោងតាមលទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេសឆ្នាំ២០១៤ បានបង្ហាញថា កម្រិតនៃវិនិយោគផ្ទាល់បរទេសត្រូវបានប៉ាន់ស្មាន មានប្រមាណ ១៩,២ ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០១៤ ដែលនាំមុខដោយវិស័យកម្មន្តសាល (២៤%) វិស័យអចលនទ្រព្យ ( ១៥% ) កសិកម្ម ( ១៤% ) វិស័យហិរញ្ញវត្ថុ ( ១២% ) វិស័យថាមពល ( ១១%) វិស័យសេវាកម្មស្នាក់នៅនិងម្ហូបអាហារ ( ១១% ) ។ល។ ប្រសិនបើពិនិត្យមើលប្រភពនៃការវិនិយោគផ្ទាល់បរទេសនៅកម្ពុជា ប្រទេសមកពីតំបន់អាស៊ី មានទំហំវិនិយោគជិត ៩០% នៃការវិនិយោគផ្ទាល់បរទេសសរុប ។ ប្រទេសចិន ( រាប់បញ្ចូលប្រទេសចិនដីគោក តៃវ៉ាន់ ហុងកុង និងម៉ាកាវ ) ជាប្រទេសមានការវិនិយោគធំជាងគេ ដែលមានសមាមាត្រប្រមាណ ៤៤ % នៃការវិនិយោគផ្ទាល់បរទេសសរុបនៅចុងឆ្នាំ២០១៤ ។ ប្រទេសវិនិយោគធំទី២ គឺប្រទេសជាសមាជិកអាស៊ាន

ដែលមានសមាមាត្រប្រមាណ ២២ % ដែលក្នុងនោះ ប្រទេសឡាវ និងមីយ៉ាន់ម៉ាពុំមានការវិនិយោគនៅក្នុងប្រទេសកម្ពុជាឡើយ ហើយការវិនិយោគផ្ទាល់ពីប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងព្រុយណេ មានចំនួនតិចតួចប៉ុណ្ណោះ ។ ប្រទេសវិនិយោគសំខាន់ៗក្នុងសមាគមន៍អាស៊ាន រួមមាន ប្រទេសវៀតណាម ម៉ាឡេស៊ី ថៃ និងសិង្ហបុរី ។ ប្រទេសកូរ៉េ និងជប៉ុន ជាប្រទេសវិនិយោគច្រើនជាងគេ ក្នុងចំណោមប្រទេសអាស៊ីផ្សេងទៀត ។ ប្រទេសនៅអឺរ៉ុបមានទំហំវិនិយោគប្រមាណ ៧ % នៃការវិនិយោគផ្ទាល់បរទេសសរុប ក្នុងនោះ សហភាពអឺរ៉ុប មានសមាមាត្រ ៨៦% នៃទំហំទឹកប្រាក់វិនិយោគរបស់ប្រទេសអឺរ៉ុបទាំងមូល ។

*ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!*

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរវាងមន្ត្រីនៃធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្នុងការយកចិត្តទុកដាក់លើការងារអង្កេតនេះរហូតទទួលបានជោគជ័យ ។ ជាមួយគ្នានេះផងដែរ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះថ្លែងនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ដល់ក្រុមហ៊ុន សហគ្រាសដែលបានចូលរួមសហការជាមួយក្រុមការងារក្នុងស្មារតីលើកកម្ពស់វិស័យស្ថិតិនៅកម្ពុជា ។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងស្ថាប័នផ្សេងទៀត ដែលបានចូលរួមចំណែកក្នុងការផ្តល់មតិយោបល់ដ៏មានតម្លៃចំពោះរបាយការណ៍នេះ និងតែងតែផ្តល់កិច្ចសហការផ្លាស់ប្តូរទិន្នន័យស្ថិតិសំខាន់ៗ ជាមួយធនាគារជាតិនៃកម្ពុជាកន្លងមក ដើម្បីជួយសម្រួលដល់ការចងក្រង និងបោះពុម្ពផ្សាយស្ថិតិជញ្ជីងទូទាត់កម្ពុជា ។ ខ្ញុំស្នើសុំដោយទទូចដល់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ មេត្តាបន្តពង្រឹងកិច្ចសហការដ៏ល្អជាប្រពៃណីជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវគុណភាពស្ថិតិកម្ពុជា និងប្រព័ន្ធស្ថិតិជាតិទាំងមូល ។

ជាទីបញ្ចប់ ខ្ញុំសូមអរគុណដល់ លោកជំទាវ **ជា សិរី** អគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា និង លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ចំពោះការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ តាំងពីពេលចាប់ផ្តើមដំណើរការអង្កេតរហូតទទួលបានជោគជ័យនាថ្ងៃនេះ ។ ជាមួយគ្នានេះដែរ ខ្ញុំសូមឆ្លៀតឱកាសនេះគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាទាំងអស់ និង **ឯកឧត្តម ឆាយ ថន** ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៃក្រសួងផែនការ ដែលតែងតែផ្តល់ការឧបត្ថម្ភគាំទ្រ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាមកលើវិស័យស្ថិតិកម្ពុជា ជាពិសេសគឺស្ថិតិវិស័យក្រៅប្រទេស និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីមកចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយ នាពេលនេះ ។

ខ្ញុំសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ ឲ្យជួបប្រទះនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាតឡើយ និងសូមប្រកាសផ្សព្វផ្សាយជាផ្លូវការនូវ **លទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!